ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

## ស្តីពី

## លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំឧសភាមាស ឆ្នាំ២០២០

នៅឧសភាមាស ឆ្នាំ២០២០នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ៖

**១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន ៖**

-បំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០។

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ**

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០៨លើក សម័យប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន០៣លើក។

**ខ-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ និងអន្តរជាតិ**

-អនុញ្ញាតឱ្យគណៈប្រតិភូជាន់ខ្ពស់ជាតិ អន្តរជាតិ និងអង្គទូតនានា ចូលជួបសម្តែងការគួរសម សវនាការ និងជម្រាបលា ចំនួន១៤លើក។

**គ-សកម្មភាពចុះមូលដ្ឋាន**

-អញ្ជើញចុះមូលដ្ឋានតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញ ចំនួន២១លើក។

**ឃ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-អញ្ជើញជាគណៈអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន៣០លើក។

**ង-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានចុះហត្ថលេខាលើព្រះរាជក្រមចំនួន០៩ច្បាប់

-បានចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន៩៤ច្បាប់

-បានទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន៨៤ច្បាប់

-បានទទួលសំណើពីរាជរដ្ឋាភិបាលចំនួន៨៣ច្បាប់

-បានទទួលសំណើពីរដ្ឋសភាចំនួន២១ច្បាប់

-បានផ្តល់យោបល់ និងចុះហត្ថលេខាលើលិខិតផ្សេងៗចំនួន២៥១ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៨១ច្បាប់។

**១.២-ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុំ កា អនុប្រធានទី១ ព្រឹទ្ធសភា បាន ៖**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភា ចំនួន០១លើក។

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ**

-អញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៨លើក សម័យប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន០៧លើក

-អញ្ជើញចូលរួមប្រជុំផ្ទៃក្នុង និងប្រជុំក្រុមសមាជិករដ្ឋសភា-ព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ចំនួន០៧លើក។

**ខ-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ និងអន្តរជាតិ**

-អនុញ្ញាតឱ្យគណៈប្រតិភូជាន់ខ្ពស់ជាតិ អន្តរជាតិ និងអង្គទូតនានា ចូលជួបសម្តែងការគួរសម សវនាការ និងជម្រាបលា ចំនួន០១លើក។

**គ-សកម្មភាពចូលរួមក្នុងពិធីផ្សេងៗ**

-អញ្ជើញជាគណៈអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន១៤លើក។

**ឃ-សកម្មភាពចុះមូលដ្ឋាន**

-អញ្ជើញចុះពិនិត្យការងារគ្រប់គ្រងសារមន្ទីរ២ធ្នូ ស្ថិតនៅភូមិជើងឃ្លូ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ។

**ង-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩០ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន១៩៤ច្បាប់ ។

**១.៣-ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន ៖**

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន១៣លើក និងសម័យប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន០៧លើក។

**ខ-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ និងអន្តរជាតិ**

-អនុញ្ញាតឱ្យគណៈប្រតិភូជាន់ខ្ពស់ជាតិ អន្តរជាតិ និងអង្គទូតនានា ចូលជួប

សម្តែងការគួរសម សវនាការ និងជម្រាបលា ចំនួន០១លើក។

**គ-សកម្មភាពចុះមូលដ្ឋាន**

-អញ្ជើញចុះមូលដ្ឋានតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញ ចំនួន០៧លើក។

**ឃ-សកម្មភាពចូលរួមក្នុងពិធីផ្សេងៗ**

-អញ្ជើញជាអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗចំនួន២១លើក។

**ង-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៩៦ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន១១៣ច្បាប់។

**២-សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍**

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានបើកសម័យប្រជុំចំនួន១៣លើក ដែលមានរបៀបវារៈដូចខាងក្រោមៈ

១.ពិនិត្យ និងសម្រេចលើសេចក្តីព្រាងច្បាប់ចំនួន២១ច្បាប់

២.ការធ្វើវិចារណកម្មថវិកាព្រឹទ្ធសភា ក្នុងក្របខ័ណ្ឌច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ចំនួន០២លើក

៣.ពិនិត្យ និងសម្រេចអំពីរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឱ្យស្របនឹងតម្រូវការថ្មីរបស់ស្ថាប័ន។

**៣.សម័យប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ**

ព្រឹទ្ធសភាបានបើកសម័យប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន០៧លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន២១ច្បាប់។

**៤-សកម្មភាពប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩**

ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការ-ដ្ឋានព្រឹទ្ធសភា បានបន្តបរិច្ចាគថវិកាផ្ទាល់ខ្លួន ប្រាក់បៀវត្សផ្ទាល់ខ្លួន គ្រឿងឧបភោគបរិភោគ និងសម្ភារៈការពារ ព្រមទាំងបានចុះអប់រំ ផ្សព្វផ្សាយអំពីវិធានការការពារ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ជូនប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

**៥-គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា**

ក្នុងឆមាស ឆ្នាំ២០២០នេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារ

យ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយឆន្ទៈ និងស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

**៥.១-មុខងារនីតិកម្ម**

គណៈកម្មការជំនាញព្រឹទ្ធសភាបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយតំណាងរាជរដ្ឋាភិបាល តំណាងរដ្ឋសភា ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ ចំនួន២១ច្បាប់។

**៥.២-មុខងារតាមដានការអនុវត្តច្បាប់**

-អញ្ជើញជួបពិភាក្សាការងារជាមួយរដ្ឋមន្ត្រីក្រសួងទេសចរណ៍, រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រុមសមាគមអ្នកចិញ្ចឹមសត្វកម្ពុជា, ប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ និងអគ្គនាយកដ្ឋានលំនៅដ្ឋាន នៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដើម្បីសិក្សាឈ្វេងយល់អំពីការរីកចម្រើនថ្មីៗ បញ្ហាប្រឈមវិធានការនានា និងស្តាប់របាយការណ៍លទ្ធផលការងារសម្រេចបានឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០

-អញ្ជើញចុះបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពី(១).ការអភិវឌ្ឍប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងបុព្វបទថ្មី ពិសេសការងារចាត់តាំង ការអនុវត្តថវិកា ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈ (២).ពិនិត្យស្ថានភាពជាក់ស្តែងរបស់ឃុំ និងពិភាក្សាដោះស្រាយទំនាស់ដីធ្លីជូនប្រជាពលរដ្ឋ (៣).ការអភិវឌ្ឍផ្លូវថ្នល់ ផ្លូវដែក កំពង់ផែទឹកជ្រៅ និងដំណើរការរោងចក្រផលិតថាមពលអគ្គិសនីដុតធ្យូងថ្ម (៤).ការអនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ (៥).ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងការអភិវឌ្ឍមូលដ្ឋាន (៦).ការវិវត្តរីកចម្រើនថ្មី និងបញ្ហាប្រឈមរបស់ខេត្ត (៧).ការផ្សព្វផ្សាយច្បាប់ (៨).ការអនុវត្តច្បាប់ និងដោះស្រាយពាក្យបណ្តឹង (៩).ការប្រមូលព័ត៌មានតាមវិស័យ (១០).ការអនុវត្តកំណែទម្រង់វិមជ្ឈការ (១១).ការគ្រប់គ្រងច្រកទ្វារអន្តរជាតិ (១២).ផ្សព្វផ្សាយអំពីតួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា និងសិក្សាឈ្វេងយល់អំពីបញ្ហាប្រឈម ព្រមទាំងសំណូមពររបស់អាជ្ញាធរមូលដ្ឋាន ក្រុមប្រឹក្សាឃុំ សង្កាត់ និង(១៣).វិស័យពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម

ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។

**៥.៣-មុខងារតំណាង**

-បានទទួលពាក្យបណ្ដឹងចំនួន៧២ករណី ធ្វើកំណត់បង្ហាញពាក្យបណ្ដឹងចំនួន៣៩ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយចំនួន៣២ករណី កំពុងពិនិត្យសិក្សាចំនួន១១ករណី ឆ្លើយតបទៅម្ចាស់បណ្ដឹងចំនួន៣៩ករណី និងបានទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្ដឹងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន០៨ករណី ព្រមទាំងបានដោះស្រាយបញ្ចប់ចំនួន០១ករណី និងតម្កល់ទុកមិនចាត់ការចំនួន០៣ករណី ទទួលឯកសារពាក្យបណ្ដឹងដែលក្រសួងស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការដើម្បីជូនជ្រាបចំនួន៩៧ករណី

-បានប្រជុំផ្សព្វផ្សាយអំពីស្មារតី នៃកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាស្ដីពី ការធ្វើវិចារណកម្មថវិកាព្រឹទ្ធសភាចំនួន០២លើក ក្នុងក្របខ័ណ្ឌច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

-បានរៀបចំវេទិកាសាធារណៈថ្នាក់ខេត្តចំនួន០៤លើកស្ដីពី (១).ការពង្រឹងសមត្ថភាពសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ ក្នុងការរៀបចំថវិកា និងការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ប្រកបដោយប្រសិទ្ធភាព (២).ការអនុវត្តតួនាទី ភារកិច្ចក្រុមប្រឹក្សាឃុំ និងសហការផ្ដល់សេវាសាធារណៈ ព្រមទាំងការអភិវឌ្ឍមូលដ្ឋាន (៣).ការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា ការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអភិវឌ្ឍមូលដ្ឋាន និង(៤).ការអភិវឌ្ឍមូលដ្ឋានជានាបាននូវការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ នៅខេត្តមណ្ឌលគិរី ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងរាជធានីភ្នំពេញ

-បានជួបសំណេះសំណាល និងដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់សមាគមបេសកកម្មសិក្សាអាស៊ី (AMSA) ប្រទេសបារាំង និងក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌នៅកម្ពុជារបស់ប្រទេសបារាំង ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅខេត្តកណ្ដាល ខេត្តព្រៃវែង ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងផ្សព្វផ្សាយវិធីបង្ការ និងទប់ស្កាត់ជំងឺកូវីដ១៩ ដល់ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តក្រុងនានាចំនួន៧៩១លើក។

**៥.៤-កិច្ចសហប្រតិបត្តិការអន្តរជាតិ**

-សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិនានាតាមរយៈប្រព័ន្ធវីដេអូ រួមមាន៖ កិច្ចប្រជុំ APA, APF, AIPA , SDGs ចំនួន០៦លើក

-លោកជំទាវ **ទី បូរ៉ាស៊ី** បានអនុញ្ញាតឱ្យលោកជំទាវ **លីយ៉ូរកា រ៉ូឌ្រីហ្គេស បារីស** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋគុយបា, ឯកឧត្តម **កេត សោផាន់** ឯកអគ្គរាជទូតតែងតាំងថ្មី នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅសាធារណរដ្ឋបារាំង, លោក Serge Bellini នាយកសាលាសម្ព័ន្ធភាពបារាំង ខេត្តសៀមរាប និងលោកស្រី Qin Deli នាយកគ្រប់គ្រងទូទៅ Cambodia Co.Ltd ចូលជួបពិភាក្សាការងារ និងសម្តែងការគួរសម

-ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** បានអញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជាទៅទស្សនកិច្ចការងារ និងពិភាក្សាអំពីការអភិវឌ្ឍលើវិស័យវេជ្ជសាស្ត្រសុខាភិបាល ដើម្បីផលប្រយោជន៍សាធារណៈ នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងដើម្បីពង្រឹងបន្ថែមទៀតនូវចំណងមិត្តភាព និងទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្មទ្វេភាគី នៅទីក្រុងហ្គុងជូ សាធារណរដ្ឋកូរ៉េ និងបានទទួលជួបគណៈប្រតិភូកូរ៉េតំណាងឱ្យក្រុមហ៊ុន HYUNDAI និងគណៈប្រតិភូមកពីសាធារណរដ្ឋប្រជាមានិតចិន ដើម្បីរកទីផ្សារនាំចេញកសិផលរបស់កសិករកម្ពុជា និងរកឱកាសបង្កើតការងារឱ្យប្រជាពលរដ្ឋកម្ពុជា

-ឯកឧត្តម **ជា ជេដ្ឋ** បានអនុញ្ញាតឱ្យលោក Larry Strange អ្នកពិគ្រោះយោបល់ និងមន្ត្រីសម្របសម្រួលក្រុមការងាររបស់វិទ្យាស្ថានសភាកម្ពុជា (PIC) ចូលជួបពិភាក្សា

ការងារស្ដីពី ការសិក្សាវាយតម្លៃពីតម្រូវការសភា

-ឯកឧត្តម **ឡៅ មុត** បានអញ្ជើញចូលរួមកិច្ចប្រជុំប្រចាំឆ្នាំនៃវេទិកាសភាអាស៊ីប៉ាស៊ីហ្វិក (APPF )លើកទី២៨ នៅទីក្រុងកង់ប៉េរ៉ា ប្រទេសអូស្ត្រាលី។

**ថ្ងៃ**សុក្រ ៧រោច **ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤**

**រាជធានីភ្នំពេញ, ថ្ងៃទី** ០៩ **ខែតុលា ឆ្នាំ២០២០**

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**កិត្តិសង្គហបណ្ឌិត ទេព ងន**

***ចម្លងជូន:***

- *ក្រសួងព្រះបរមរាជវាំង*
- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្ដីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *(ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*